# ការវិភាគគោលនយោបាយសង្ខេបអំពីថវិកាអប់រំ ឆ្នាំ២០១៨

## *ដំណោះស្រាយចំពោះឧបសគ្គផ្នែកការចំណាយ សម្រាប់ការសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ របស់សិស្សប្រុសនិងសិស្សស្រីមកពីគ្រួសារក្រីក្រ ជនបទ និងតំបន់ដាច់ស្រយាល*

## សេចក្តីផ្តើម

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើកំណែទម្រង់គោលនយោបាយអប់រំទូលំទូលាយ និងកិច្ចខិតខំដើម្បីបង្កើនថវិកាអប់រំ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ។ ទោះបីជាយ៉ាងនេះក្តី មកទល់បច្ចុប្បន្ននេះ ការវិនិយោគក្នុងវិស័យអប់រំនៅពុំទាន់ឈានដល់កម្រិតស្តង់ដារសាកល ក្នុងអត្រា ២០% នៃថវិកាជាតិសរុប[1] ដូចមានចែងក្នុងសេចក្តីប្រកាស និងក្របខ័ណ្ឌសកម្មភាព ទីក្រុងអ៊ីនឈាន់នៅឡើយ[2]។ បន្ថែមលើនេះទៀត កំណើនការចំណាយគិតជាភាគរយសរុបដ៏ច្រើនសម្រាប់វិស័យអប់រំ ត្រូវបានស្រូបយកដោយកំណើនការចំណាយសម្រាប់បុគ្គលិក (PE) (ឧ. ប្រាក់បៀវត្សបុគ្គលិក ការចំណាយពាក់ព័ន្ធនឹងបុគ្គលិក) និងការចំណាយជាប្រចាំដទៃទៀត។ ទិដ្ឋភាពនេះ បានធ្វើឱ្យការបង្កើនការវិនិយោគដែលអាចផ្តល់ផលដោយផ្ទាល់ដល់សិស្សជាពិសេស គឺសិស្សមកពីគ្រួសារក្រីក្រ ជនបទ និងតំបន់ដាច់ស្រយាល នៅមានកម្រិត។

ជាផ្នែកមួយនៃការបន្តផ្តោតការយកចិត្តទុកដាក់រួមគ្នា ដើម្បីបង្កើនការវិនិយោគផ្នែកការអប់រំឱ្យកាន់តែច្រើន និងមានសមធម៌ថែមទៀត អង្គការសង្គ្រោះកុមារ (Save the Children) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) និងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ក្រោមជំនួយបច្ចេកទេសពីក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល បានធ្វើការសិក្សាមួយ ដើម្បីឱ្យយល់កាន់តែច្បាស់ថែមទៀត អំពីផលប៉ះពាល់នៃឧបសគ្គផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុចំពោះការសិក្សាថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិសម្រាប់កុមារី និងកុមារាមកពីគ្រួសារក្រីក្រ[3] ក្នុងខេត្តដែលមានភូមិសាស្ត្រ និងស្ថានភាពសង្គមសេដ្ឋកិច្ចខុសប្លែកពីគ្នាចំនួនបួន រួមមានខេត្តកំពង់ចាម កោះកុង ព្រះវិហារ និងពោធិ៍សាត់។ ការប្រមូលទិន្នន័យបានធ្វើឡើងចាប់ពីខែឧសភា ដល់ខែកក្កដា ឆ្នាំ ២០១៨ លើគ្រួសារចំនួន ៤៨៦ គ្រួសារ ដោយប្រើប្រាស់ឧបករណ៍ស្ទង់មតិគ្រួសារខ្នាតតូច។ បន្ថែមលើនេះ ក៏មានការប្រមូលទិន្នន័យបែបគុណភាពតាមរយៈការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះជាមួយប្រធានក្រុមប្រឹក្សាឃុំ ៤រូប នាយកសាលា ១០រូប និងមន្ត្រីអប់រំស្រុក ៤រូប ព្រមទាំងតាមរយៈការពិភាក្សាក្រុមគោលដៅសរុបទាំងអស់ ២៧ក្រុម ជាមួយឪពុកម្តាយ និងសិស្សនៅក្នុងសហគមន៍ដែលមានការចុះស្ទង់មតិ និងបានផ្ទៀងផ្ទាត់ជាមួយលទ្ធផលពីការស្ទង់មតិ។

លទ្ធផលវិភាគបានបង្ហាញថា មានភាពប្រសព្វគ្នារវាងកត្តាផ្នែកហិរញ្ញវត្ថុ និងកត្តាមិនមែនហិរញ្ញវត្ថុដែលនាំឱ្យមានការបោះបង់ការសិក្សា សម្រាប់ទាំងកុមារី និងកុមារានៅថ្នាក់បឋមសិក្សា និងជាពិសេស គឺនៅថ្នាក់មធ្យមសិក្សាបឋមភូមិ។ កត្តាទាំងអស់នេះមានដូចជា ការខ្វះខាតប្រាក់ (ចំណូលរបស់គ្រួសារ/ភាពក្រីក្រ) ឧបសគ្គផ្នែកហិរញ្ញវត្ថុដែលពាក់ព័ន្ធដទៃទៀត និងលទ្ធផលការរៀន

សូត្រអន់ខ្សោយ[4]។ នៅក្នុងការពិភាក្សាក្រុមគោលដៅ (FGDs) កុមារី និងកុមារាស្ថិតក្នុងអាយុរៀនថ្នាក់មធ្យមសិក្សាបឋមភូមិ (ព្រមទាំងកុមារី និងកុមារាតិចតួចនៅថ្នាក់បឋមសិក្សា) បញ្ជាក់ថា មានតម្រូវការចំពោះមុខដែលទាមទារឱ្យពួកគេត្រូវចូលរួមក្នុងសកម្មភាពរកចំណូលទាំងនៅក្នុងផ្ទះ និងនៅក្រៅផ្ទះ ដើម្បីបំពេញបន្ថែមដល់ជីវភាពរស់នៅដ៏ផុយស្រួយរបស់ឪពុកម្តាយខ្លួន។ សេចក្តីត្រូវការក្នុងការជួយរក្សានិរន្តរភាពចំណូលគ្រួសារ គឺជាកត្តាដ៏គួរជាទីកត់សម្គាល់ដែលបណ្តាលឱ្យមានការបោះបង់ការសិក្សាពីការអប់រំក្នុងប្រព័ន្ធ។ លទ្ធផលនេះ ឆ្លើយតបទៅនឹងលទ្ធផលប្រហាក់ប្រហែលគ្នានៅក្នុងការស្រាវជ្រាវថ្នាក់សហគមន៍មួយ ដែលធ្វើឡើងដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ស្តីពីសិទ្ធិទទួលបានការអប់រំ ក្នុងឆ្នាំ ២០១៤[5] និង ការពិនិត្យឡើងវិញលើផ្នែកគោលនយោបាយស្តីពីសុខុមាលភាពយុវជនឆ្នាំ ២០១៧ ក្នុងប្រទេសកម្ពុជាដោយអង្គការ OECD[6]។ ការសិក្សាខាងក្រោយនេះ បានកត់សម្គាល់ថា "យុវជនមកពីគ្រួសារក្រីក្របំផុតក្នុងប្រទេសកម្ពុជា មានអត្រាចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សាទាបជាងគេបំផុត"។

ការស្រាវជ្រាវនេះបង្ហាញថា ឥរិយាបថ និងទស្សនៈយល់ឃើញជាអវិជ្ជមានរបស់ឪពុកម្តាយលើគុណតម្លៃនៃការអប់រំ ទាំងសម្រាប់កុមារី និងកុមារា (តាមការឆ្លុះបញ្ចាំងឱ្យឃើញដោយឪពុកម្តាយ និងរាយការណ៍ដោយសិស្សនៅក្នុង FGDs) ហាក់មានផលប៉ះពាល់ស្តួចស្តើងចំពោះការបោះបង់ការសិក្សា។ ទោះយ៉ាងណាក្តី ការជះឥទ្ធិពលរបស់ឪពុកម្តាយ ហាក់ដើរតួនាទីខ្លាំងដោយប្រយោល ដោយសារតែសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុរបស់គ្រួសារ ជាជាងដោយសារតែទស្សនៈយល់ឃើញអំពីគុណតម្លៃនៃការសិក្សា ភាពខុសប្លែកគ្នាផ្នែកយេនឌ័រ និងលទ្ធភាពរូបវន្តក្នុងការទៅសាលារៀន។ អ្នកផ្តល់ចម្លើយនៅខេត្តទាំងបួនបានបង្ហាញជាឯកច្ឆ័ន្ទថា ការរៀនសូត្រមានសារៈសំខាន់សម្រាប់កូនៗរបស់ពួកគេ។ ដូចគ្នាដែរ ៩៥% នៃអ្នកផ្តល់ចម្លើយបានបញ្ជាក់ថា ការចូលរៀននៅវិទ្យាល័យមានសារៈសំខាន់ដូចគ្នាសម្រាប់កូនប្រុស និងកូនស្រីរបស់ពួកគេ។ មូលហេតុចម្បងនៃការបោះបង់ការសិក្សានៅសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិបញ្ជាក់ដោយអ្នកផ្តល់ចម្លើយមានដូចតទៅៈ "ការបោះបង់ការសិក្សាដោយជម្រើសផ្ទាល់ខ្លួន ការខ្វះខាតលុយកាក់ និងកុមារត្រូវធ្វើការដើម្បីផ្គត់ផ្គង់ប្រាក់ចំណូលគ្រួសារ"។

## អនុសាសន៍

ផ្អែកលើលទ្ធផលពីការវិភាគនេះ ព្រមទាំងការស្រាវជ្រាវយ៉ាងទូលំទូលាយផ្សេងទៀតស្តីពីសមធម៌ថវិកាអប់រំ ធ្វើឡើងដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) និងស្ថាប័នដទៃទៀត យើងខ្ញុំសូមជូនអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡាៈ

១. បែងចែកកញ្ចប់ថវិកាជាតិ ២០% សម្រាប់ការចំណាយរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបទៅតាមកម្រិតស្តង់ដាសាកល ដោយបង្កើនការវិនិយោគប្រកបដោយសមធម៌សម្រាប់អ្នកសិក្សានៅតាមបណ្តាខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់។

២. កសាងសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងសាលារៀន និងការធ្វើផែនការថវិកា និងបង្កើនការវិនិយោគលើការផ្តល់សៀវភៅពុម្ព សម្ភារៈបង្រៀន និងរៀន និងសម្ភារៈការិយាល័យសម្រាប់សាលារៀននៅតាមបណ្តាខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់ ដើម្បីឱ្យការចំណាយទាំងអស់នោះមិនត្រូវក្លាយជាបន្ទុកគ្រួសារក្រីក្រ។

៣. ដោះស្រាយបញ្ហាខ្វះគ្រូនៅក្នុងតំបន់ជនបទ និងដាច់ស្រយាល និងបង្កើនការវិនិយោគលើការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា និងការចំណាយលើការបង់ថ្លៃរៀនគួរសម្រាប់គ្រួសារក្រីក្រ ដោយសារតែគុណភាពបង្រៀន និងរៀនអន់ខ្សោយ។

៤. វិនិយោគលើការផ្តល់ និងការបង្កើនឱកាស "ការរៀនសូត្រក្រៅប្រព័ន្ធ" និងកិច្ចគាំពារសង្គម (ដូចជា អាហារូបករណ៍សម្រាប់សិស្សមកពីគ្រួសារដែលមានប័ណ្ណក្រីក្រ) ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា ដោយផ្តោតការយកចិត្តទុកដាក់លើភាពខុសគ្នារវាងកុមារានិងកុមារី និងធានាឱ្យអ្នកសិក្សាដែលបោះបង់ការសិក្សាក្នុងមធ្យមសិក្សាបឋមភូមិ អាចអភិវឌ្ឍបំណិនជីវិត និងជំនាញសម្រាប់មុខរបរ ដើម្បីទទួលបានការងារសមរម្យ។

## ១. បែងចែកកញ្ចប់ថវិកាជាតិ ២០% សម្រាប់ការចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបទៅតាមកម្រិតស្តង់ដាសាកល ដោយបង្កើនការវិនិយោគប្រកបដោយសមធម៌សម្រាប់អ្នកសិក្សានៅតាមបណ្តាខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់។

ផ្អែកលើការវិភាគរបស់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលលើថវិកាអប់រំឆ្នាំ ២០១៧ យើងហាក់ឃើញមានកង្វះការវិនិយោគប្រកបដោយសមធម៌ក្នុងវិស័យអប់រំនៅតាមបណ្តាខេត្តទាំងអស់។ ឧទាហរណ៍ ថវិកាពុំមែនជាប្រាក់បៀវត្សគិតតាមសមាមាត្រសិស្ស ដែលបានចុះឈ្មោះចូលរៀនក្នុងខេត្តពោធិ៍សាត់ និងព្រះវិហារ គឺមានកម្រិតទាបជាងខេត្តកោះកុង ថ្វីបើខេត្តទាំងពីរនេះ មានអត្រាភាពក្រីក្រខ្ពស់ជាងខេត្តកោះកុងក្តី ដែលចង្អុលបង្ហាញឱ្យឃើញនូវតម្រូវការឱ្យមានការវិនិយោគកាន់តែច្រើន និងមានសមធម៌ថែមទៀតនៅក្នុងថវិកាថ្នាក់ខេត្ត។

**តារាងទី ១៖ ការបែងចែកថវិកាអប់រំធៀបទៅនឹងអត្រាភាពក្រីក្រក្នុងខេត្ត ឆ្នាំ ២០១៧**

| | ខេត្តកំពង់ចាម | ខេត្តកោះកុង | ខេត្តពោធិ៍សាត់ | ខេត្តព្រះវិហារ |
|---|---|---|---|---|
| អត្រាភាពក្រីក្រ (%) | ១៧,៣២ | ១៤,៥៧ | ២៣,១៦ | ២៨,៦៧ |
| ថវិកាអប់រំសម្រាប់សិស្សដែលបានចុះឈ្មោះម្នាក់ (ដុល្លារអាមេរិច) | ១៦៩,៤ | ២៥១,៥ | ១៧៥,៣ | ២១២,៣ |
| ថវិកាពុំមែនជាប្រាក់បៀវត្សសម្រាប់អ្នកសិស្សដែលបានចុះឈ្មោះម្នាក់ (ដុល្លារអាមេរិច) | ១៧,២៧ | ៤៨,៧ | ១៩,៤ | ៣៧,០ |

**ប្រភពព័ត៌មាន៖** ការវិភាគរបស់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលលើថវិកាអប់រំឆ្នាំ ២០១៧

បន្ថែមលើនេះទៀត យើងខ្ញុំសូមជូនអនុសាសន៍ថា កំណើនការវិនិយោគក្នុងវិស័យអប់រំ ត្រូវអមមកជាមួយនូវតម្លាភាពថវិកា និងការពន្យល់ឱ្យបានច្រើនថែមទៀត។ ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើតយន្តការសម្រាប់បង្ហាញអំពីការចំណាយជាសាធារណៈ និងលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានស្តីពីថវិកាអប់រំនៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តថវិកា និងគ្រប់កម្រិតអភិបាលកិច្ចទាំងអស់។ ការធ្វើបែបនេះ អាចជួយសម្រួលដល់ការឆ្លុះបញ្ចាំងអំពីអាទិភាព និងគម្លាតសេវា ដែលបានរកឃើញដោយប្រជាពលរដ្ឋ តាមរយៈការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម (ISAF) និងពង្រឹងផែនការសកម្មភាពគណនេយ្យភាពរួម (JAAP)។ ការវិនិយោគកាន់តែច្រើនឡើងក្នុងវិស័យអប់រំ រួមជាមួយតម្លាភាពថវិកា នឹងអាចជួយបង្កើនការចូលរួមពីសាធារណជន និងបង្កើនការគាំទ្រជាសាធារណៈចំពោះកិច្ចខិតខំកំណែទម្រង់របស់ក្រសួងលើការទទួលបានការអប់រំ និងការអប់រំប្រកបដោយគុណភាព។

## ២. កសាងសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងសាលារៀន និងការធ្វើផែនការថវិកា និងបង្កើនការវិនិយោគលើការផ្តល់សៀវភៅពុម្ព សម្ភារៈបង្រៀន សម្ភារៈសិក្សា និងសម្ភារៈការិយាល័យសម្រាប់សាលារៀននៅតាមបណ្តាខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់ ដើម្បីកុំឱ្យការចំណាយទាំងអស់នោះក្លាយជាបន្ទុកគ្រួសារក្រីក្រ។

ការវិភាគទៅលើផែនការសកម្មភាពគណនេយ្យភាពរួម (JAAP) សរុបចំនួន ៨១២ (ក្នុងឃុំចំនួន ៨១២ ក្នុងខេត្តចំនួន ១៨) ដែលបានមកពីការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម (ISAF) ក្នុងឆ្នាំ ២០១៧ បញ្ជាក់ឱ្យឃើញថា ការផ្តល់សៀវភៅពុម្ពក្នុងចំនួនគ្រប់គ្រាន់សម្រាប់សិស្សម្នាក់ៗ គឺជាអាទិភាពចម្បងរបស់ ពលរដ្ឋ និងមន្ត្រីមូលដ្ឋាន[7]។ បទដ្ឋានសម្រាប់ការផ្តល់សៀវភៅពុម្ពនៅក្រោម JAAP គឺសៀវភៅពុម្ព ៣ ក្បាលសម្រាប់សិស្សម្នាក់ចំពោះសិស្សចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៣ និងសៀវភៅ ៥ ក្បាលសម្រាប់សិស្សម្នាក់ចំពោះសិស្សចាប់ពីថ្នាក់ទី ៤ ដល់ថ្នាក់ទី ៦។ ទោះយ៉ាងណាក្តី ការវិភាគបង្ហាញឱ្យឃើញថា បទដ្ឋាននេះពុំត្រូវបានឆ្លើយតបទេនៅតាមសាលារៀនជាច្រើន។ បន្ថែមលើនេះទៀត ទិន្នន័យស្ទង់មតិដែលបានមកពីបណ្តាខេត្តទាំងបួនបានចង្អុលបង្ហាញថា ការចំណាយសម្រាប់ការប៉ះប៉ូវបន្ថែមលើសម្ភារៈផ្គត់ផ្គង់សាលារៀន និងសម្ភារៈការបង្រៀន និងការរៀន ត្រូវបានក្លាយជាបន្ទុករបស់គ្រួសារក្រីក្រ ដែលធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានសម្រាប់សិស្សទាំងនៅថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សាបឋមភូមិ។ ឪពុកម្តាយដែលបានចូលរួមក្នុងការសិក្សារបស់ NEP ក្នុងឆ្នាំ ២០១៤ បានបញ្ជាក់ថា "កង្វះសម្ភារៈសិក្សា គឺជាបុព្វហេតុចម្បងមួយនៃការមករៀនមិនទៀងទាត់ និងជាមូលហេតុធ្វើឱ្យកុមារបោះបង់ការសិក្សា"។

យើងខ្ញុំសូមជូនជាអនុសាសន៍ដល់ក្រសួងអប់រំ យុវជន និងកីឡា បន្តវិនិយោគក្នុងការកសាងជំនាញ និងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកផ្នែកការគ្រប់គ្រងសាលារៀន និងការធ្វើផែនការថវិកា ដើម្បីធានាឱ្យបានថា សម្ភារៈបង្រៀន និងសម្ភារៈសិក្សាត្រូវបានគណនាបញ្ចូលយ៉ាងគ្រប់គ្រាន់សម្រាប់ការធ្វើផែនការថវិកា។ បន្ថែមលើនេះទៀត ការរៀបចំថវិកានៅកម្រិត សាលារៀន និងការគ្រប់គ្រងសាលារៀន គួរមានការចូលរួមរបស់គ្រូ និងអ្នកតំណាងសហគមន៍ ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាព។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់ NEP ក្នុងឆ្នាំ ២០១៨[8] ស្តីពីការធ្វើផែនការថវិកាសាលារៀនបានរកឃើញថា ប្រមាណ ៧០% នៃនាយកសាលា ៦៥% នៃគណនេយ្យករ ៥៨,៥% នៃគ្រូបង្រៀន និង ៧៣% នៃអ្នកតំណាងគណៈកម្មាធិការទ្រទ្រង់សាលារៀន (SSC) បានបញ្ជាក់ថាពួកគេធ្លាប់ជួបបញ្ហាប្រឈមក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍សាលារៀន។ នាយកសាលាចំនួន ៥៦,៦% ដែលត្រូវបានស្ទង់មតិនៅក្នុងការសិក្សានោះ ទទួលស្គាល់ថា ពួកគាត់ខ្វះចំណេះដឹង និងការយល់ដឹងអំពីវិធីសាស្ត្រក្នុងការធ្វើផែនការថវិកា។

៣. ដោះស្រាយបញ្ហាខ្វះគ្រូនៅក្នុងតំបន់ជនបទ និងដាច់ស្រយាល និងបង្កើនការវិនិយោគលើការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា និងការចំណាយលើការបង់ថ្លៃរៀនគួរសម្រាប់គ្រួសារក្រីក្រ ដោយសារតែគុណភាពបង្រៀន និងរៀនអន់ខ្សោយ។

មន្ត្រីថ្នាក់ស្រុក មេឃុំ នាយកសាលា និងអ្នកសិក្សាមកពីថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិជាច្រើន ដែលបានចូលរួមក្នុងការសិក្សានេះ បាននិយាយអំពីកង្វះគ្រូនៅតាមសាលារៀនតាមតំបន់ជនបទ។ អ្នកចូលរួមជាច្រើននៅក្នុងការសម្ភាសន៍ផ្តល់ព័ត៌មានគន្លឹះ (KIIs) និង FGDs ទាំងមូល បានកត់សម្គាល់ថា កង្វះគ្រូ គឺភាគច្រើនលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។ ជាលទ្ធផល គ្រូមិនមានជំនាញត្រូវបានស្នើសុំឱ្យបង្រៀនមុខវិជ្ជាគណិតវិទ្យា។ លទ្ធផលក៏បានបញ្ជាក់ផងដែរថា "កត្តារុញច្រាន" ចម្បងមួយដែលធ្វើឱ្យសិស្សបោះបង់ការសិក្សា (សម្រាប់ថ្នាក់បឋមសិក្សា និងកាន់តែច្រើនថែមទៀតនៅថ្នាក់មធ្យមសិក្សាបឋមភូមិ) គឺលទ្ធផលរៀនសូត្រខ្សោយ ដោយសារគ្រូបង្រៀនមិនមានគុណវុឌ្ឍិគ្រប់គ្រាន់ និងមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់។ លទ្ធផលការសិក្សាខ្សោយនេះ ត្រូវបានស្តែងឱ្យឃើញយ៉ាងច្បាស់តាមរយៈសមត្ថភាពក្នុងការអានរបស់សិស្សនៅថ្នាក់ទាបៗទូទាំងប្រទេសកម្ពុជានៅមានភាពទន់ខ្សោយ ដូចបានឃើញនៅក្នុងការវាយតម្លៃសមត្ថភាពអំណាននៅថ្នាក់ដំបូង (EGRA) ក្នុងឆ្នាំ ២០១០ ថ្វីបើមានភាពរីកចម្រើនគួរជាទីកត់សម្គាល់នៃពិន្ទុ EGRA ឆ្នាំ ២០១២[9] ផ្អែកលើកម្មវិធីសិក្សាថ្មីក្តី។

បន្ថែមលើនេះទៀត ការវាយតម្លៃគុណភាពការបង្រៀននៅថ្នាក់ដំបូងក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៧ ធ្វើឡើងដោយអង្គការ NEP[10] បង្ហាញឱ្យឃើញថា "ថ្វីបើគ្រូជាច្រើនអាចប្រឡងជាប់តេស្តកម្រិតសិក្សារបស់សិស្ស និងមានការយល់ដឹងជាមូលដ្ឋានអំពីទស្សនាទានគណិតវិទ្យាក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់ទី ១ ដល់ ថ្នាក់ទី ៣ ក្តី ប៉ុន្តែមានគ្រូបង្រៀនមួយចំនួនដែលមិនអាចបង្ហាញសូម្បីតែកំរិតយល់ដឹងជាមូលដ្ឋានអំពីឯកសារក្នុងមុខវិជ្ជាដែលខ្លួនបង្រៀន"។ នាយកសាលាដែលបានចូលរួមក្នុងការសិក្សាឆ្នាំ ២០១៧ របស់ NEP នេះ បានកំណត់ថា "មានតម្រូវការខ្ពស់ឱ្យមានការបណ្តុះបណ្តាលគ្រូបង្រៀនអំពីបច្ចេកទេសគ្រប់គ្រងថ្នាក់រៀន ការអនុវត្តក្នុងការបង្រៀនគណិតវិទ្យា និងមានតម្រូវការពីកម្រិតមធ្យមទៅកម្រិតខ្ពស់ ឱ្យមានការបណ្តុះបណ្តាលអំពីការវាយតម្លៃសិស្ស"។

ក្នុងការសិក្សារបស់យើង សិស្ស និងឪពុកម្តាយ បានពិពណ៌នាអំពីការបង្រៀន និងការរៀនដែលពួកគាត់បានសង្កេតឃើញ ឬបានទទួលបទពិសោធន៍ថា "ជាការបង្រៀនតែនៅក្នុងថ្នាក់រៀន/ផ្អែកទ្រឹស្តី" ដោយគ្មានការអនុវត្តផ្ទាល់លើមុខវិជ្ជាវិទ្យាសាស្ត្រ អាស្រ័យដោយកង្វះជំនាញឯកទេសរបស់គ្រូ ឬកង្វះឧបករណ៍ដែលត្រូវការ។ ម្យ៉ាងវិញទៀត គុណភាពនៃការបង្រៀន និងការសិក្សាខ្សោយ ហាក់ដះឥទ្ធិពលយ៉ាងសម្បើមលើសិស្សក្នុងថ្នាក់ទី ៧ ដល់ ថ្នាក់ទី ៩ ដែលត្រូវជួបបញ្ហាប្រឈមកាន់តែខ្លាំងថែមទៀតក្នុងការចាប់យកទស្សនាទានក្នុងគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា លើសពីសិស្សដទៃទៀតក្នុងកម្រិតថ្នាក់ទាបជាងនេះ។ សិស្សជាច្រើនបានជ្រើសរើសការបោះបង់ការសិក្សាដោយខ្លួនឯង ដោយបានលើកឡើងថាខ្លួនពុំមានសមត្ថភាពយល់មេរៀនដែលបានបង្រៀន ជាមូលហេតុនៃការបោះបង់ការសិក្សា។

ការវិនិយោគមិនគ្រប់គ្រាន់លើគុណភាពនៃការបង្រៀន និងការសិក្សា ជាពិសេសនៅតាមជនបទដាច់ស្រយាល ក៏បានផ្តល់លទ្ធផលឱ្យមានការធ្វើឯកជនភាវូបនីយកម្មលើការបង្រៀនដោយបន្ទុកការចំណាយត្រូវបានធ្លាក់លើគ្រួសារក្រីក្រ។ គ្រូជាច្រើនដែលជានិយោជិករបស់រដ្ឋ បានផ្តល់ការបង្រៀនថ្នាក់ក្រៅម៉ោង (ជារឿយៗបង្រៀនដល់សិស្សរបស់ខ្លួនឯង)។ ការសិក្សារបស់អង្គការ UNDP លើការបង្រៀនគួរ និងថ្លៃសិក្សាក្រៅផ្លូវការក្នុងការអប់រំថ្នាក់មូលដ្ឋានរបស់កម្ពុជាក្នុងឆ្នាំ ២០១៤[11] ក៏បានកត់សម្គាល់ប្រហាក់

ប្រហែលគ្នានេះដែរថា "ក្នុងចំណោមមុខចំណាយសម្រាប់ឪពុកម្តាយភាគច្រើន ថ្លៃរៀនគួរគឺជាសមាសធាតុដ៏ធំដែលតំណាងឱ្យមុខចំណាយចំនួន៤ក្នុងចំណោមមុខចំណាយទាំង ១១ ដែលឪពុកម្តាយត្រូវបង់"។

ដើម្បីចាត់វិធានការគោលនយោបាយដ៏ចាំបាច់ក្នុងការឆ្លើយតបទៅនឹងគុណភាពមិនគ្រប់គ្រាន់ក្នុងការបង្រៀន និងការរៀននេះ ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនការវិនិយោគក្នុងការបណ្តុះបណ្តាលគ្រូមុនពេលចូលបំពេញការងារ និងក្នុងពេលកំពុងបំពេញការងារ ដោយផ្តល់អាទិភាពដល់តំបន់ជនបទ និងដាច់ស្រយាល។ ការងារនេះ ក៏ទាមទារឱ្យមានការវិនិយោគផ្នែកហិរញ្ញវត្ថុឱ្យបានកាន់តែច្រើនពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងថវិកាអប់រំខេត្តសម្រាប់មន្ត្រីអប់រំ ដើម្បីចុះទៅតាមសាលារៀនពិនិត្យតាមដានគុណភាពនៃការបង្រៀន និងការរៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ជាផ្នែកមួយនៃកម្មវិធីវាយតម្លៃការអនុវត្តការងាររបស់គ្រូឱ្យកាន់តែទូលំទូលាយថែមទៀត។

៤. វិនិយោគលើការផ្តល់ និងការបង្កើនឱកាស "ការរៀនសូត្រក្រៅប្រព័ន្ធ" និងកិច្ចគាំពារសង្គម (ដូចជា អាហារូបករណ៍សម្រាប់សិស្សមកពីគ្រួសារដែលមានប័ណ្ណក្រីក្រ) ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា ដោយផ្តោតការយកចិត្តទុកដាក់លើភាពខុសគ្នារវាងកុមារា និងកុមារី និងជានាឱ្យសិស្សដែលបោះបង់ការសិក្សាក្នុងមធ្យមសិក្សាបឋមភូមិអាចអភិវឌ្ឍបំណិនជីវិត និងជំនាញសម្រាប់មុខរបរ ដើម្បីទទួលបានការងារសមរម្យ។

នៅក្នុងការសិក្សារបស់យើង អ្នកផ្តល់ចម្លើយជាច្រើនបានបង្ហាញថា សិស្សថ្នាក់បឋមសិក្សានិងមធ្យមសិក្សាបឋមភូមិជាច្រើនបោះបង់ការសិក្សាដោយសារការបាត់បង់ឱកាសស្វែងរកចំណូលដោយសារការទៅសាលារៀន បើទោះបីជាពួកគេជាអ្នកទទួលបានអាហារូបករណ៍ពីកម្មវិធីផ្តល់អាហារូបករណ៍សម្រាប់សិស្សមកពីគ្រួសារមានប័ណ្ណក្រីក្រក៏ដោយ។ យើងសង្កេតឃើញថាអត្រានៃការបោះបង់ការសិក្សារបស់កុមារានៅក្នុងគ្រប់កំរិតសិក្សាមានខ្ពស់ជាងកុមារី បើយោងទៅតាមស្ថិតិ និងសូចនាករអប់រំសារជារណៈ ២០១៦-២០១៧[12]។ អាហារូបករណ៍អាចជួយសម្រួលបញ្ហាបាត់បង់ឱកាសស្វែងរកចំណូលដោយសារការទៅសាលារៀនសម្រាប់កុមាររស់នៅក្នុងភាពក្រីក្របាន ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រហែលជាទាមទារឱ្យមានការវាយតម្លៃឱ្យបានដាប់លាប់ដោយមានរួមបញ្ចូលបញ្ហាយេនឌ័រផងដែរទៅលើប្រសិទ្ធភាព និងយន្តការផ្តល់អាហារូបករណ៍នេះ។

ផ្អែកលើទិន្នន័យបែបគុណភាពនៅក្នុងការសិក្សានេះ បង្ហាញថា សិស្សដែលបានបោះបង់ការសិក្សានៅថ្នាក់មធ្យមសិក្សាបឋមភូមិជួបការលំបាកក្នុងការស្វែងរកច្រកផ្លូវរៀនសូត្រជាជម្រើសជំនួសផ្សេងទៀត។ ឪពុកម្តាយ និងសិស្សនៅក្នុង FGDs ក្នុងការសិក្សានេះ បានបញ្ជាក់ថា ឱកាសទទួលបានការអប់រំបំប៉ន និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) មានកម្រិតកំណត់នៅក្នុងសហគមន៍ជនបទដាច់ស្រយាលនៅក្នុងការសិក្សានេះ។ បន្ថែមពីនេះទៀត ឱកាសចូលទៅក្នុងកម្មវិធី TVET ភាគច្រើនហាក់តម្រូវឱ្យមានការសិក្សាយ៉ាងហោចណាស់ដល់ថ្នាក់ទី ៩។ ក្រសួងអប់រំ យុវជន និងកីឡា គួរពង្រីកគោលនយោបាយនាពេលបច្ចុប្បន្ន ដូចជា ការអភិវឌ្ឍផ្នែកជំនាញបច្ចេកទេស និង ជំនាញទន់សម្រាប់សមាសធាតុយុវជននៅក្នុងផែនការយុទ្ធសាស្ត្រការអប់រំឆ្នាំ ២០១៤-២០១៨ របស់ក្រសួង ដើម្បីកែលម្អបំណិនជីវិត និងជំនាញដែលអាចរកការងារធ្វើបាននៅក្នុងសាលារៀន។ ក្រសួងអប់រំ ក៏គួរពង្រីកការវិនិយោគបន្ថែមទៀត នៅក្នុងកម្មវិធីចូលរៀនឡើងវិញ កម្មវិធីរៀនបំប៉ន និងការគាំទ្របន្ថែមទៀតដល់កម្មវិធីអប់រំក្រៅប្រព័ន្ធដែលបច្ចុប្បន្នមាននៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ (ដោយរួមមានទាំងថ្នាក់អក្ខរកម្ម ព្រមទាំងឱកាសរៀនសូត្រដទៃទៀត)។ សិស្សដែលបានបោះបង់ការសិក្សានៅថ្នាក់មធ្យមសិក្សាបឋមភូមិ អាចប្រើប្រាស់ឱកាសទាំងអស់នេះ ដើម្បីអភិវឌ្ឍបំណិនជីវិត និងបំណិនផ្នែកមុខរបរ ដើម្បីទទួលបានការងារសមរម្យ និងប្រាក់ចំណូលនាពេលអនាគត។

បញ្ជីរាយនាមអង្គការសង្គមស៊ីវិលដែលចូលរួមក្នុងការវិភាគ និងគាំទ្រលទ្ធផលនៃការវិភាគ៖

1. អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
2. អង្គការយេនឌ័រ និងការអភិវឌ្ឍន៍កម្ពុជា (GADC)
3. អង្គការអុកស្វាមកម្ពុជា ( Oxfam Cambodia )
4. អង្គការសង្គ្រោះកុមារអន្តរជាតិប្រចាំនៅកម្ពុជា (SCI)
5. អង្គការស្មាកម្ពុជា (SK)
6. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NOGF)
7. អង្គការតម្លាភាពអន្តរជាតិកម្ពុជា (TIC)
8. អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា (SVC)
9. អង្គការជំនួយជនបទ (RAO)
10. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA)
11. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia)
12. អង្គការសកម្មភាពពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA)
13. អង្គការអភិវឌ្ឍន៍កុមារ និងសហគមន៍ក្រីក្រ (CPCDO)
14. អង្គការបំរើសេវាសង្គមដើមឈើសប្បាយ (Happy Tree)
15. អង្គការកុមារគេតព្រំដែនកម្ពុជា (KnK)
16. អង្គការគ្រួសារថ្មី (KT)
17. អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌ (KYCC)
18. មជ្ឈមណ្ឌលការពារសិទ្ធិកុមារកម្ពុជា ( CCPCR)
19. សមគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា (SFODA)
20. អង្គការសុវណ្ណកុមារ ( Sovann Komar)
21. អង្គការវឌ្ឍនភាព (WP)
22. គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព ( HACC )

[1] យោងតាមខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៩ ថវិកាក្រសួងអប់រំស្មើនឹង១៣,៧% នៃថវិកាជាតិសរុប។
http://www.mef.gov.kh/documents/mustsee/Executive_Summary_2019_Final.pdf?fbclid=IwAR2xoGsjmF8r3-Ry9E9W-Qf4vYUEOdGT29agrr-NbrscWLfcnR8sHWeW8rg

[2] Incheon Declaration and Framework for Action for the implementation of Sustainable Development Goal 4, available at http://unesdoc.unesco.org/images/0024/002456/245656e.pdf

[3] សម្រាប់អង្គការ Save the Children ភាពក្រីក្ររបស់កុមារ មាន "ទិដ្ឋភាពផ្សេងៗ" គ្នា ហើយប៉ះពាល់ដល់កុមារគ្រប់វ័យទាំងអស់ និងពុំមែនវាស់វែងតែតាមរយៈប្រាក់ចំណូលតែមួយមុខឡើយ។ ហេតុនេះ អង្គការ Save the Children ពិនិត្យមើលទិដ្ឋិភាពផ្សេងៗជាច្រើនដែលភាពក្រីក្រជះឥទ្ធិពលលើជីវិតរបស់កុមារ ដូចជាបញ្ហាសុខភាព និងកង្វះអាហារូបត្ថម្ភ កង្វះលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ កង្វះការអប់រំ និងលទ្ធផលការរៀនសូត្រខ្សោយ កង្វះលទ្ធភាពទទួលបានសេវាជាសារវន្ត ប្រឈមមុខជាមួយការងារប្រកបដោយគ្រោះថ្នាក់ អំពើហិង្សា ឬ ការរឹតបន្តឹងទៅលើបំលាស់ទី។ ដូច្នេះ ថ្វីបើការវាយតម្លៃនេះ ផ្តោតការយកចិត្តទុកដាក់លើឧបសគ្គផ្នែកហិរញ្ញវត្ថុ (ប្រាក់ចំណូល) ក្នុងការទៅសាលារៀនសម្រាប់គ្រួសារក្រីក្រ ក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្តី ប៉ុន្តែទិដ្ឋភាពមួយចំនួននៃភាពក្រីក្ររបស់កុមារ ក្នុងចំណោមទិដ្ឋភាពខាងលើ ត្រូវបានដាក់បញ្ចូលឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាននៅក្នុងការសិក្សានេះ។

[4] ឧបសគ្គផ្នែកហិរញ្ញវត្ថុរួមមានដូចជា ការចំណាយលើឯកសណ្ឋាន សៀវភៅ អាហារនៅសាលារៀន មធ្យោបាយធ្វើដំណើរ ហើយអ្វីដែលសំខាន់ជាងនេះ គឺការបាត់បង់ឱកាសស្វែងរកចំណូលដោយសារការទៅសាលារៀន។

[5] NGO Education Partnership, 2014. Right to Education in Cambodia: Community Level Research.
Available at http://memlib.nepcambodia.org/libraries

[6] OECD, 2017. 'Youth Well-being Policy Review of Cambodia', EU-OECD Youth Inclusion Project, Paris. Available at https://www.oecd.org/countries/cambodia/Youth-well-being-policy-review-Cambodia.pdf

[7] ការវិភាគនេះ ត្រូវបានធ្វើឡើងរួមគ្នាដោយបណ្តា NGO ចំនួនប្រាំដែលកំពុងអនុវត្ត ISAF ក្នុងនោះមានអង្គការ RACHA អង្គការ ទស្សនៈពិភពលោកអន្តរជាតិប្រចាំប្រទេសកម្ពុជា អង្គការសង្គ្រោះកុមារប្រចាំប្រទេសកម្ពុជា អង្គការឃែកម្ពុជា និង STAR Kampuchea។

[8] NGO Education Partnership, 2018. Performance budgeting at the primary school level in Cambodia.
Available at http://memlib.nepcambodia.org/libraries

[9] Research Triangle Institute, 2015. Cambodia Education Sector Early Grade Reading Assessment Report. Prepared for United States Agency for International Development, Cambodia. Available at https://pdf.usaid.gov/pdf_docs/pa00krtd.pdf

[10] NGO Education Partnership, 2017. An Assessment of Early Grade Teaching Quality in Cambodia.
Available at http://memlib.nepcambodia.org/libraries

[11] UNDP, 2014. Curbing Private Tutoring and Informal Fees in Cambodia's Basic Education. UNDP: Cambodia.
Available at
http://www.kh.undp.org/content/dam/cambodia/docs/PovRed/Curbing%20Private%20Tutoring%20and%20Informal%20Fee%20in%20Cambodia%20Basic%20Education.pdf

[12] MoEYS, 2017. Public Education Statistics & Indicators 2016-2017. Available at http://www.moeys.gov.kh/en/emis/2461.html#.W9I8XZMzaUk